**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ០៤៥ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៥

# ប្រកាស
## ស្តីពីការអនុវត្តន៍វិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.កប ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ៣១៩ សហវ.ប.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-យោងកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់អោយអនុវត្តជាផ្លូវការនា ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤

-យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៥ លើលិខិតលេខ ៧២២៧ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

## សំរេច

**ប្រការ១** : ប្រគល់សិទ្ធិសំរេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ជូនក្រសួងស្ថាប័ន-ខេត្តក្រុង និងសហគ្រាសសាធារណៈ ក្នុងកំរិតទឹកប្រាក់ធានាចំណាយ ដូចខាងក្រោម :

-ក្រោមទឹកប្រាក់ ២០០លានរៀល សំរាប់ថវិកាមន្ទីរជំនាញខេត្ត-ក្រុង

-ក្រោមទឹកប្រាក់ ៣០០លានរៀល សំរាប់ថវិកាសាលាខេត្ត-ក្រុង

-ក្រោមទឹកប្រាក់ ៥០០លានរៀល សំរាប់ថវិកាក្រសួង-ស្ថាប័ន និង សហគ្រាសសាធារណៈលក្ខណៈរដ្ឋបាល

-ក្រោមទឹកប្រាក់ ១០០០លានរៀល សំរាប់ថវិកាក្រសួងអប់រំយុវជន និង កីឡា ក្រសួងសុខាភិបាល និង សហគ្រាសសាធារណៈលក្ខណៈសេដ្ឋកិច្ច ។

**ប្រការ២** : កំណត់ វិធីសាស្ត្រលទ្ធកម្មសាធារណៈតាមកំរិតទឹកប្រាក់ដូចខាងក្រោមៈ

-ក្រោមទឹកប្រាក់២០លានរៀល អនុវត្តវិធីសាស្ត្រទិញផ្ទាល់ (Direct Purchase-DP) ឬ ចុះ កិច្ចសន្យាផ្ទាល់ (Direct Contracting-DCO)

-ទឹកប្រាក់ចាប់ពី ២០លានរៀលដល់ក្រោម ៥០លានរៀល អនុវត្តវិធីសាស្ត្រស្ទង់តំលៃក្នុងស្រុក (Domestic Convassing-DC) ។

-ទឹកប្រាក់ចាប់ពី៥០លានរៀលឡើងទៅអនុវត្តវិធីសាស្ត្រដេញថ្លៃសាធារណៈ ។

**ប្រការ៣** : ភារកិច្ចទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង-សហគ្រាសសាធារណៈក្នុងក្របខណ្ឌ វិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈដែលចែងក្នុងប្រការ១មានដូចខាងក្រោម :

ក- ត្រូវអនុវត្តអោយបានម៉ឹងម៉ាត់ត្រឹមត្រូវសមស្របតាមអនុក្រឹត្យលេខ ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ប្រកាសលេខ ៣១៩ សហវ.បប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ និងបទប្បញ្ញត្តិលទ្ធកម្មផ្សេងទៀតជាធរមាន ។

ខ- មិនត្រូវបំបែកគំរោងចំណាយដែលជាក់ស្តែង សមស្រប ត្រូវអនុវត្តការងារ និង ធ្វើកិច្ចលទ្ធកម្ម តែមួយលើកអោយទៅជាច្រើនលើកដើម្បីត្រូវតាមសិទ្ធិសំរេចទទួលខុសត្រូវរបស់ខ្លួន ។

គ- ត្រូវរៀបចំកិច្ចលទ្ធកម្ម មួយឆ្នាំម្តង ឬ មួយឆមាសម្តង ផ្អែកតាមគោលការណ៍ធានាចំណាយ និង អនុវត្តអោយបាន រួសរាន់នៅដើមឆ្នាំ ឬ ដើមឆមាស ។

ឃ- ត្រូវអោយមានទទួលការបណ្តុះបណ្តាលជំនាញមុនធ្វើការជ្រើសតាំងជាប្រធានអង្គភាពលទ្ធកម្ម ។

ង- ត្រូវរៀបចំ និងអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ដោយអង្គភាពលទ្ធកម្ម ( អល -PU) ក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា ( គបវប-PEAC) ។

ច- ត្រូវរៀបចំទំរង់បែបបទ និង ខ្លឹមសារឯកសារលទ្ធកម្មសាធារណៈអោយបានសមស្របតាមគំរូឯកភាពណែនាំ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ( នាយក ដ្ឋានលទ្ធកម្មសាធារណៈ) ។

ឆ- ត្រូវរៀបចំឯកសារដេញថ្លៃតាមគំរូឯកភាពណែនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( នាយកដ្ឋាន

លទ្ធកម្មសាធារណៈ) ។ ឯកសារដេញថ្លៃត្រូវបានពិនិត្យ និងបញ្ជាក់ឯកភាពពីប្រធានក្រសួងស្ថាប័ន-ខេត្ត-ក្រុង និង សហគ្រាសសាធារណៈមុនប្រកាស ដាក់អោយដេញថ្លៃ ។

ជ- ត្រូវកំណត់សំរេចតំលៃប្រគល់កិច្ចសន្យាអោយសមស្រប ទាបជាង ឬ ប្រហាក់ប្រហែលនិងតំលៃលក់ដុំទីផ្សារ ។

ឈ- ត្រូវអោយអង្គភាពលទ្ធកម្ម(អល-PU)ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(នាយកដ្ឋានលទ្ធកម្មសាធារណៈ) ១ខែម្តង នូវរបាយការណ៍លទ្ធកម្មតាមគំរូឯកភាពណែនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយភ្ជាប់ មកជាមួយនូវៈ កិច្ចសន្យា ,តារាង តំលៃ,តារាងប្រៀបធៀបតំលៃទីផ្សារ ។

**ប្រការ៤ :** ការអនុវត្តនីតិការកិច្ច និងការទទួលខុសត្រូវ ដូចមានចែងក្នុងប្រការ៣ ជាលក្ខណ៍មូលដ្ឋានសំខាន់សំរាប់ ត្រួតពិនិត្យ និង វាយតម្លៃ នូវគុណសម្បត្តិ-គុណវិបត្តិ របស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ និងបង្កើនការិតទឹកប្រាក់ផ្តល់វិសហមជ្ឈការសំរាប់ជំហ៊ានបន្តបន្ទាប់ទៀត។

**ប្រការ៥ :** ភារកិច្ចទទួលខុសត្រូវរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្មសាធារណៈ) ក្នុងក្របខណ្ឌ័វិសហមជ្ឈការ កិច្ចលទ្ធកម្ម ដូចមានចែងក្នុងប្រការ១ មាន ដូចខាងក្រោម :

ក- ណែនាំអំពីគោលការណ៍ និងការអនុវត្តនីតិ កិច្ចលទ្ធកម្មសាធារណៈ ជូនក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ ស្របតាមអនុក្រិត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេង១ជាធរមាន។

ខ- ពិនិត្យកែសំរួលបទប្បញ្ញត្តិលទ្ធកម្ម មានស្រាប់អោយបានសមស្រប និងពង្រឹងរបៀបរបបការងារសំដៅអនុវត្តកិច្ចលទ្ធកម្ម នៅតាមបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈអោយមានតម្លាភាព និងប្រសិទ្ធិភាពប្រសើរឡើង ។

គ- រៀបចំផែនការ និង ធ្វើការបណ្តុះបណ្តាលមុខជំនាញ លទ្ធកម្ម ជូនដល់អង្គភាពលទ្ធកម្ម (អល-PU) និងគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតំលៃ និងប្រគល់កិច្ចសន្យា (គបវប-PEAC) ។

ឃ- ចុះត្រួតពិនិត្យ និងពង្រឹងការអនុវត្តនីតិកិច្ចលទ្ធកម្មសាធារណៈ និងមានវិធានការកែលំអឱ្យបានសមស្របតាមបទប្បញ្ញត្តិលទ្ធកម្មជាធរមាន។

ង- ទប់ស្កាត់ និងមានវិធានការចំពោះភាពមិនប្រក្រតីក្នុងដំណើរការអនុវត្តកិច្ចលទ្ធកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ។

ច- ត្រួតពិនិត្យរបាយការណ៍លទ្ធកម្ម និង សកម្មភាពអនុវត្ត របស់ក្រសួងស្ថាប័ន ខេត្ត-ក្រុងសហគ្រាសសាធារណៈ និងធ្វើការវាយតំលៃបូកសរុបលទ្ធផល។

ឆ- ត្រួតពិនិត្យឡើងវិញការអនុវត្តកិច្ចលទ្ធកម្ម នៅក្រសួង ខេត្ត-ក្រុង-សហគ្រាសសាធារណៈ ដែលបានអនុវត្តរួចកាល់។

**ប្រការ៦ :** ចំពោះកិច្ចលទ្ធកម្មដែលទឹកប្រាក់ធានាចំណាយលើសពីទឹកប្រាក់ការិតសិទ្ធិសំរេចដូចចែងក្នុងប្រការ១ ក្រសួងស្ថាបន័ ខេត្ត-ក្រុង សហគ្រាសសាធារណៈ ត្រូវរក្សាការអនុវត្តនីតិវិធីសាស្ត្រ និងនីតិវិធីដូចកាលកន្លងមក ដោយត្រូវបញ្ជូន ឯកសារដេញថ្លៃ ឯកសារវាយតម្លៃប្រគល់កិច្ចសន្យា និង កិច្ចសន្យាដើម្បីសុំការពិនិត្យ ផ្តល់ទិដ្ឋការ និង ការសំរេចយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាម រយៈ នាយកដ្ឋានលទ្ធកម្មសាធារណៈ ។ ការបើក

ឯកសាដេញថ្លៃ និង ការប្រគល់ទទួលត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្មសាធារណៈ) ។

**ប្រការ៧ :** ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង សហគ្រាសសាធារណៈត្រូវមានវិធានការម៉ឺងម៉ាត់ និងដាក់ទោសពិន័យ តាមបទប្បញ្ញត្តិជាធរមានចំពោះមន្ត្រីរាជការ និង ក្រុមហ៊ុនអាជីវកម្ម ដែលបាន អនុវត្តខុសឆ្គង ឬ រំលោភ បំពានលើវិធីសាស្ត្រ និងនិតិវិធីលទ្ធកម្មសាធារណៈ ។

**ប្រការ៨ :** រាល់បទប្បញ្ញត្តិ ទាំងឡាយណាពាក់ពន្ធ័ក្នុងកិច្ចលទ្ធកម្មសាធារណៈសំរាប់ក្រសួងស្ថាបន័ ខេត្ត-ក្រុង និង សហគ្រាសសាធារណៈដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៩ :** គ្រប់ក្រសួង ស្ថាបន័ ខេត្ត-ក្រុង សហគ្រាសសាធារណៈ ព្រមទាំងនាយកដ្ឋាន អង្គភាពពាក់ពន្ធ័ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជារបាយការណ៍"

- គ្រប់ក្រសួងស្ថាបន័ ខេត្ត-ក្រុង-សហគ្រាសសាធារណៈ
- នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ